**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០០៥/២៦ ក.ប/ខ.ស

## សារលិខិតជូនពរ

**សូមគោរពជូន**

**ឯកឧត្តម ហ៊ី សោភា ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

ក្នុងឱកាសចម្រើនជន្មាយុដ៏ជ័យមង្គលដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៦ នេះ ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមប្រសិទ្ធពរជ័យជូនចំពោះ **ឯកឧត្តម** ទទួលបាននូវបញ្ញាញាណភ្លឺថ្លាវាងវៃ កម្លាំងពលំមាំមួន ជន្មាយុយឺនយូរ និងសម្រេចជោគជ័យដ៏ត្រចះត្រចង់ក្នុងបេសកកម្មដឹកនាំក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឱ្យសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត ជាពិសេស ការធានាបាននូវធម្មនុញ្ញភាព តម្លាភាព និងនីតិរដ្ឋនៅកម្ពុជា សំដៅបម្រើឱ្យឧត្តមប្រយោជន៍ជាតិ និងប្រជាជនខ្មែរបានរស់នៅរួមគ្នាយ៉ាងសុខដុមរមនាក្រោមម្លប់សន្តិភាព។ នៅក្នុងកាលៈទេសៈនៃការឈ្លានពានរបស់កងកម្លាំងប្រដាប់អាវុធថៃមកលើដែនអធិបតេយ្យភាពជាតិកម្ពុជា **ឯកឧត្តម** និង**លោកជំទាវ** បានចូលរួមជាកម្លាំងដ៏មហាសាមគ្គីជាតិ រួមនឹងវីរយុទ្ធជន គាំទ្រនិងជឿជាក់យ៉ាងមុតមាំលើយុទ្ធសាស្ត្រការពារជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រកបដោយទឹកចិត្តស្នេហាជាតិ និងស្មារតីមោះមុតក្នុងកិច្ចការពារព្រំដែន ដើម្បីបុព្វហេតុការពារជាតិមាតុភូមិ។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្ទសាធុការពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរ ជូនចំពោះ **ឯកឧត្តម** និង**លោកជំទាវ** ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ សូមសមប្រកបដោយព្រះពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម ហ៊ី សោភា ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវភក្តីភាពដ៏ស្មោះស្ម័គ្រពីយើងខ្ញុំ។

ថ្ងៃ ពុធ ១១រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០២៦

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩